# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

Mr. Tim Theang, father of Ven. Indapanna Tim Sakhorn, on Aug. 12, 2008, personally and on behalf of his family, humbly requests the Cambodian King, His Majesty Norodom Sihamoni to intervene in repatriating his son from VN to the Kingdom of Cambodia. Ven. Tim Sakhorn is a Khmer citizen and has lived in Cambodia since 1979 before the incidence; Samdech Tep Vong ordered his promotion and demotion as Temple Chief.

## ក្រាបបង្គំទូលថ្វាយ

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី

## ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ទូលព្រះបង្គំជាខ្ញុំ ទឹម ធឿង ជាឪពុកបង្កើតទឹម សាខន អតីតព្រះចៅអធិការវត្តភ្នំដិនខាងជើង ឃុំ ភ្នំដិន ស្រុក គីរីវង់ ខេត្តតាកែវ សូមក្រាបថ្វាយបង្គំព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូងជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ !

ទូលព្រះបង្គំជាខ្ញុំ តំណាងឲ្យក្រុមគ្រួសារទាំងមូល សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ព្រះរាជទានជ្រាបថា ទឹម សាខន កូនរបស់ទូលព្រះបង្គំជាខ្ញុំ ដែលត្រូវសម្តេចព្រះសង្ឃរាជបញ្ជាចាប់ផ្សឹកកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧ ហើយបញ្ជូនទៅឲ្យតុលាការប្រទេសវៀតណាមកាត់ទោសឲ្យជាប់ពន្ធនាគារនៅប្រទេសវៀតណាមនោះ ឥឡូវនេះអាជ្ញាធរវៀតណាមបានដោះលែងវិញហើយ ប៉ុន្តែពុំអនុញ្ញាតមកជួបជុំក្រុមគ្រួសារនៅព្រះរាជាណាចក្រកម្ពុជាវិញទេ ដោយឲ្យស្នាក់នៅក្នុងផ្ទះសាច់ញាតិនាភូមិអណ្តូងទរ ឃុំ អណ្តូងទរ(បាជុក) ស្រុក ស្វាយទង (ទ្រីតូង) ខេត្ត មាត់ជ្រូក ក្រោមការការពារយ៉ាងតឹងរឹងបំផុតពីប៉ូលិសវៀតណាម ដោយពុំអនុញ្ញាតទាក់ទងមជ្ឈដ្ឋានខាងក្រៅឡើយ។ ម្យ៉ាងទៀតកូនរបស់ទូលព្រះបង្គំកំពុងមានជម្ងឺជាទម្ងន់ទៀតផង។

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយខាងលើ ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំអង្វរករព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមព្រះមេត្តាប្រោសព្រះរាជទានព្រះរាជអន្តរាគមន៍ ដើម្បីឲ្យទឹម សាខន កូនរបស់ទូលព្រះបង្គំជាខ្ញុំ បានវិលត្រឡប់មកជួបជុំក្រុមគ្រួសារនៅព្រះរាជាណាចក្រកម្ពុជា និងបានព្យាបាលជម្ងឺ ដោយព្រះរាជទានប្រោស ! ទូលព្រះបង្គំជាខ្ញុំនឹកកូនខ្លាំងណាស់។

សូមថ្វាយព្រះពរព្រះករុណាជាអម្ចាស់ជីវិតលើត្បូង មានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណវៀងវៃ ព្រះជន្មយឺនយូរជាងរយព្រះវស្សា ដើម្បីប្រថាប់ជាម្លប់ពីត្រជាក់ដល់ប្រជានុរាស្ត្រខ្មែរនៅគ្រប់ទិសទីតរៀងទៅ។

សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ។

សេចក្តីពុំគួរសូមព្រះរាជទានប្រោស !

ក្រាបបង្គំទូលថ្វាយនៅភូមិភ្នំដិន ឃុំ ភ្នំដិន ស្រុក គីរីវង់ ខេត្តតាកែវ

ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៨

ទឹម ធឿង

www.khmerkromngo.org